ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**សូមទូលថ្វាយ**
**ព្រះអង្គម្ចាស់ក្សត្រិយ៍ នរោត្តម ម៉ារី រណឫទ្ធិ**
**និងព្រះរាជបុត្រា បុត្រីគ្រប់ព្រះអង្គ**

ព្រះអង្គម្ចាស់ក្សត្រិយ៍ ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ទូលព្រះបង្គំ និងភរិយា ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកគ្រប់ជាន់ថ្នាក់នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងមន្ត្រីការទូតកម្ពុជាទាំងអស់ ដែលកំពុងបំពេញបេសកកម្មការទូតនៅបរទេស មានសេចក្តីក្តុកក្តួល និងសោកស្តាយក្រៃលែង បន្ទាប់ពីបានទទួលដំណឹងដ៏សែនរន្ធត់ក្រៀមក្រំអំពីការយាងសោយទិវង្គតរបស់ **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងជាព្រះប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ** នៅថ្ងៃអាទិត្យ ៩រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ក្នុងព្រះជន្មាយុ ៧៧ ព្រះវស្សា ដោយព្រះរោគាពាធ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ ទូលព្រះបង្គំ និងភរិយា សូមចូលរួមរំលែកព្រះមរណទុក្ខជាមួយព្រះអង្គម្ចាស់ក្សត្រិយ៍ជាព្រះជាយា និងព្រះរាជបុត្រា បុត្រី ព្រមទាំងរាជវង្សានុវង្ស ប្រកបដោយក្តីសង្វេគសោកស្តាយស្រណោះអាឡោះអាល័យជាទីបំផុត ព្រោះថាការបាត់បង់ **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** គឺជាការបាត់បង់ព្រះរាជឥស្សរជនក្នុងព្រះរាជវង្សដ៏ឆ្នើមមួយព្រះអង្គ ដែលទ្រង់ពេញព្រះហឫទ័យ ស្នេហាជាតិ សាសនា ព្រះមហាក្សត្រ ប្រកបដោយព្រះឆន្ទៈមនសិការមោះមុត និងវាងវៃជាអតិបរមា។

ទន្ទឹមនេះ ទូលព្រះបង្គំ និងភរិយា ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកគ្រប់ជាន់ថ្នាក់នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមលំឱនកាយវាចាចិត្តឧទ្ទិសកុសលបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ យាងដង្ហែព្រះវិញ្ញាណក្ខន្ធ **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** សូមព្រះអង្គយាងបានសោយសុខក្នុងសុគតិភពគ្រប់ៗ ព្រះជាតិកុំបីឃ្លៀងឃ្លាតឡើយ។

សូម ព្រះអង្គម្ចាស់ក្សត្រិយ៍ជាព្រះជាយា និងព្រះរាជបុត្រា បុត្រី ព្រមទាំងព្រះញាតិវង្សានុវង្ស មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីទូលព្រះបង្គំ។

ថ្ងៃ **អង្គារ ១១រោច** ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី**៣០** ខែវិច្ឆិកា ឆ្នាំ២០២១

**ប្រាក់ សុខុន**

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
Ministry of Foreign Affairs
and International Cooperation



## សូមថ្វាយមហាព្រះកុសល

ព្រះវិញ្ញាណក្ខន្ធ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ
សូមព្រះអង្គយាងទៅកាន់ព្រះបរមសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ

១៩៤៤ - ២០២១